**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៣ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីប្រកួតកីឡាវាយកូនគោល ដើម្បីមូលនិធិសង្គ្រោះជនក្រីក្រ និងងាយរងគ្រោះ កម្ពុជា ឡាវ វៀតណាម

*** ``` ***

- យោងតាមសំណូមពរ និងការងារចាំបាច់

**<u>សម្រេច</u>**

**ប្រការ ១.-** បង្កើតគណៈកម្មការរៀបចំពិធីប្រកួតកីឡាវាយកូនគោល ដើម្បីមូលនិធិសង្គហសង្គ្រោះជនក្រីក្រ និងងាយរងគ្រោះ កម្ពុជា ឡាវ វៀតណាម ដែលនឹងប្រព្រឹត្តទៅនៅក្លឹបវាយកូនគោល ឡុង ថាញ់ និងនិវេសនដ្ឋាន (Long Thanh Golf Club and Residential Estate) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម<br>ជា **ប្រធាន** |
| ២- | ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍<br>ជា **អនុប្រធាន** |
| ៣- | ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ជា **សមាជិក** |
| ៤- | ឯកឧត្តម | **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន<br>ជា **សមាជិក** |
| ៥- | ឯកឧត្តម | **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា<br>ជា **សមាជិក** |
| ៦- | ឯកឧត្តម នាយឧត្តមសេនីយ៍ | **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ<br>ជា **សមាជិក** |

៧- ឯកឧត្តម **សួស យ៉ារ៉ា** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជា **សមាជិក**

**ប្រការ ២.-** គណៈកម្មការនេះ មានភារកិច្ចរៀបចំកម្មវិធី ការផ្សព្វផ្សាយ ការរៃអង្គាសប្រមូលមូលនិធិ ការធ្វើដំណើរ ការហូបចុក ស្នាក់នៅរបស់កីឡាករ និងធុរជន ដែលបានចូលរួមក្នុងពិធីប្រកួតកីឡាវាយកូនគោល ដើម្បីមូលនិធិសង្គហសង្គ្រោះជនក្រីក្រ និងងាយរងគ្រោះ កម្ពុជា ឡាវ វៀតណាម នេះឱ្យប្រព្រឹត្តទៅបានល្អប្រសើរ ហើយអាចបង្កើតអនុគណៈកម្មការជំនាញជាជំនួយការតាមការចាំបាច់។

**ប្រការ ៣.-** សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**